# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៥ សហវ

## ប្រកាស

ស្តីពី

ការផ្លាស់ប្តូរសមាជិកក្រុមការងារ

សំរាប់គំរោងអភិវឌ្ឍន៍កសិកម្មក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF)

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងខ្ចីបុល រវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៩៦
- បានឃើញប្រកាសលេខ ៤០៦ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបង្កើតក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្ម ក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF)
- បានឃើញប្រកាសលេខ ៤៧០ សហវ.វស ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០០ របស់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបន្ថែមសមាជិកក្រុមការងារសំរាប់គំរោងអភិវឌ្ឍន៍កសិកម្មក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ1445-CAM (SF)
- បានឃើញភាពចាំបាច់របស់ក្រសួង

# សម្រេច

**ប្រការ១:** ផ្លាស់ប្តូរសមាជិកចំនួន០២រូប ក្នុងក្រុមការងារសំរាប់គំរោងការអភិវឌ្ឍន៍កសិកម្ម " Agriculture Sectors Program Loan" ក្រោមឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1445-CAM (SF) ពីឈ្មោះ :

១ - លោក អ៊ុយ ឈឺន ទៅលោក ឈួន សិរីវិទ្ធិ អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី

២ - លោក ឃុន ហ្សូលីន ទៅលោក ទេព សៀង មន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី

**ប្រការ២:** ភារកិច្ចរបស់សមាជិកដែលផ្លាស់ចូលថ្មីនេះ មានចែងនៅក្នុង" ប្រការ២" នៃប្រកាសលេខ ៤០ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២ ដូចបានយោងខាងលើ ។

**ប្រការ៣:** អគ្គលេខាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន:**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- ក្រសួងធនធានទឹក និងឧតុនិយម
- ឯកសារ